PESTECH

# ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក

# របាយការណ៍ប្រចាំត្រីមាស

## ត្រីមាសទី ២ សម្រាប់ឆ្នាំហិរញ្ញវត្ថុ

## ដែលបានបញ្ចប់នៅ

## ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២៣

PESTECH

# ទិន្នន័យហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ | | ត្រីមាសទី២ ឆ្នាំ ២០២៣ (លានរៀល) | ឆ្នាំ ២០២២ (លានរៀល) | ឆ្នាំ ២០២១ (លានរៀល) |
|---|---|---|---|---|
| ទ្រព្យសកម្មសរុប | | ១ ២២៥ ៦៦៩ | ១ ២០២ ២៨២ | ១ ១៦៦ ៨៨២ |
| បំណុលសរុប | | ១ ១២០ ៣៩៥ | ១ ០៩២ ២៦៦ | ១ ០៧២ ៩៨៥ |
| មូលធនសរុប | | ១០៥ ២៧៤ | ១១០ ០១៦ | ៩៣ ៨៩៧ |
| **ចំណេញ/ (ខាត)** | | **ត្រីមាសទី២ ឆ្នាំ ២០២៣ (លានរៀល)** | **ត្រីមាសទី២ ឆ្នាំ ២០២២ (លានរៀល)** | **ត្រីមាសទី២ ឆ្នាំ ២០២១ (លានរៀល)** |
| ចំណូលសរុប | | ១៩ ១០៦ | ៥៨ ២៧៤ | ៣៥ ៩២៤ |
| (ខាត)/ចំណេញមុនបង់ពន្ធ | | (១ ៧៦៩) | ១ ៣២៤ | (១ ៦៥៧) |
| ចំណេញប្រតិបត្តិការ | | ៤ ៩៧៣ | ៦ ០៧២ | ៥ ៣០៧ |
| (ខាត)/ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ | | (២ ២៩៧) | ៦៥៦ | (១ ៦៦៩) |
| ចំណេញ/(ខាត)សរុបលម្អិត | | (៥ ០៧៧) | ៣ ៣៦០ | (១ ០៥០) |
| **អនុបាតហិរញ្ញវត្ថុ** | | **ត្រីមាសទី២ ឆ្នាំ ២០២៣** | **ឆ្នាំ ២០២២** | **ឆ្នាំ ២០២១** |
| អនុបាតសាធនភាព | | (០,២៩%) | ១,៦៨% | ២,៤០% |
| អនុបាតសាធនភាព (ប្រាក់កម្ចីទូទៅ)* | | (១,៩២%) | ១៥,៩៥% | ៤៩,៩៣% |
| អនុបាតសន្ទនីយភាព | អនុបាតចរន្ត | ០,៩៩ | ០,៩៣ | ០,៩០ |
| | អនុបាតចរន្តលឿន | ០,៩២ | ០,៩២ | ០,៨៨ |
| | | **ត្រីមាសទី២ ឆ្នាំ ២០២៣** | **ត្រីមាសទី២ ឆ្នាំ ២០២២** | **ត្រីមាសទី២ ឆ្នាំ ២០២១** |
| អនុបាតចំណេញភាព | អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម | (០,១៩%) | ០,០៥% | (០,១៦%) |
| | អនុបាតចំណេញធៀបនឹងមូលធន | (២,១៨%) | ០,៦៥% | (២,០៩%) |
| | អនុបាតគម្លាតចំណេញដុល | ៤៧,៧៦% | ១៦,៥០% | ២៥,១៨% |
| | អនុបាតគម្លាតចំណេញភាព | (១២,០២%) | ១,១៣% | (៤,៦៥%) |
| | ចំណេញក្នុងមួយឯកតាមូលបត្រ កម្មសិទ្ធិ(ករណីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ) (រៀល) | (៣០,៦៥) | ៨,៧៥ | (២២,៤៩) |
| អនុបាតលទ្ធភាពបង់ការប្រាក់ | | ០,៥២ | ០,៧៨ | ០,៧៥ |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (ប្រសិនមាន) (ករណីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ) | | គ្មាន | គ្មាន | គ្មាន |
| អនុបាតហិរញ្ញវត្ថុសំខាន់ៗផ្សេងទៀត (ប្រសិនមាន) | | គ្មាន | គ្មាន | គ្មាន |

PESTECH

* កម្ចីសម្រាប់ដំណើរការអាជីវកម្មធម្មតាមិនរាប់បញ្ចូលលក្ខខណ្ឌកម្ចីរយៈពេលវែង ដែលបានធានាដោយដំណើរការនៃគម្រោងទូទាត់ពន្យាពេល ដែលមានកិច្ចព្រមព្រៀងទូទាត់ដោយផ្ទាល់ជាមួយអគ្គីសនីកម្ពុជា(EDC)។ កម្ចីសម្រាប់ដំណើរការអាជីវកម្មធម្មតាមានចំនួន ៦៣ ៨៧៤ លានរៀល (ឆ្នាំ ២០២២៖ ៤៣ ៨៨១ លានរៀល)និង កម្ចីរយៈពេលវែងមានចំនួន ៣៥៨ ៤៦៣ លានរៀល គិតត្រឹម ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២២ (ឆ្នាំ ២០២២៖ ៣៧២ ៦៩២ លានរៀល) ។

PESTECH

# សមាសភាពក្រុមប្រឹក្សាភិបាល



PESTECH

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

ជូនចំពោះភាគហ៊ុនិក

សម្ព័ន្ធក្រុមហ៊ុនបានបិទបញ្ចប់ត្រីមាសទីពីរ (២) ("Q២") នៃឆ្នាំហិរញ្ញវត្ថុ ("FY") ២០២៣ ជាមួយនឹងលទ្ធផលហិរញ្ញវត្ថុដែលប្រសើរឡើង បើទោះបីជាសេចក្តីរាយការណ៍អំពីឱនភាពបន្ទាប់ពីការគិតគូរតួលេខពន្ធ ដោយសារស្ថានភាពទីផ្សារមិនអំណោយផលនៅតែបន្តកើតមានលើប្រតិបត្តិការរបស់សម្ព័ន្ធក្រុមហ៊ុន។

ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច រួមទាំងការដំឡើងការប្រាក់ និងការគំរាមកំហែងអតិផរណាដែលជិតមកដល់ បានបន្តជះឥទ្ធិពលអូសបន្លាយដល់សម្ព័ន្ធក្រុមហ៊ុន ទាំងផ្នែកហិរញ្ញវត្ថុ និងប្រតិបត្តិការផងដែរ។

ដោយហេតុនេះ ប្រាក់ចំណូលសរុបបានថយចុះមកនៅត្រឹម ១៩,១០៦ ពាន់លានរៀល បើធៀបនឹង ៣២,៧៥៦ ពាន់លានរៀល។ ទោះជាយ៉ាងណាក៏ដោយ យើងបានគ្រប់គ្រងក្នុងការចុះបញ្ជីប្រាក់ចំណេញប្រតិបត្តិការដែលមានចំនួន ៤,៩៧៣ ពាន់លានរៀល ដែលមានការប្រសើរឡើងរហូតទៅដល់១០២% ប្រៀបធៀបនឹងត្រីមាសមុនក្នុងឆ្នាំហិរញ្ញវត្ថុ ២០២៣ ។ យើងក៏បានធ្វើឲ្យការខាតមុនបង់ពន្ធ("LBT")កាន់តែតិចជាងមុន ដែលមានចំនួន ១,៧៦៩ ពាន់លានរៀល ធៀបនឹង LBT នៃត្រីមាសមុនសម្រាប់ឆ្នាំហិរញ្ញវត្ថុដដែល ដែលមានចំនួន ៤,៨៦៧ ពាន់លានរៀល។ ក្នុងន័យនេះដែរ យើងក៏បានបង្រួមការខាតក្រោយបង់ពន្ធមកត្រឹមតែ ២,២៩៧ ពាន់លានរៀល ក្នុង Q២ នៃឆ្នាំហិរញ្ញវត្ថុ ២០២៣ ដែលមានការប្រសើរឡើងរហូតដល់ ៥៧% ប្រៀបធៀបនឹងត្រីមាសទី ១ សម្រាប់ឆ្នាំហិរញ្ញវត្ថុដដែល។

គណៈគ្រប់គ្រងបានកំពុងធ្វើការយ៉ាងសកម្មដើម្បីព្យាយាមឆ្ពោះទៅរកការផ្លាស់ប្តូរមួយ ហើយសង្ឃឹមថានឹងអាចផ្តល់នូវលទ្ធផលហិរញ្ញវត្ថុវិជ្ជមាននៅក្នុងត្រីមាសនាពេលអនាគត។ យើងតែងតែយកចិត្តទុកដាក់លើឱកាសទីផ្សារនៅក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធថាមពល ជាពិសេសនៅក្នុងប្រទេសកម្ពុជា។ និរន្តរភាពនៃការរីកចម្រើនសម្រាប់សម្ព័ន្ធក្រុមហ៊ុនអាស្រ័យលើសមត្ថភាពរបស់សម្ព័ន្ធក្រុមហ៊ុនក្នុងការទទួលបានគម្រោងថ្មីៗជាបន្តបន្ទាប់ ធានាបាននូវហិរញ្ញប្បទានដែលជាតម្រូវការ និងធានាថាក្រុមការងារដែលទទួលបន្ទុកផ្នែកប្រតិបត្តិអាចអនុវត្តគម្រោងប្រកបដោយប្រសិទ្ធផល និងប្រសិទ្ធភាព។ ក្នុងន័យនេះដែរ យើងចង់ធានាដល់ភាគហ៊ុនិករបស់យើងថា សម្ព័ន្ធក្រុមហ៊ុនប្រកាន់ខ្ជាប់នូវការប្តេជ្ញាចិត្តក្នុងការរក្សាជំហររបស់យើងក្នុងនាមជាអ្នកចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍន៍គម្រោងហេដ្ឋារចនាសម្ព័ន្ធថាមពលនៅក្នុងប្រទេសកម្ពុជា។

ជាចុងក្រោយ យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះភាគហ៊ុនិក អតិថិជន អ្នកផ្គត់ផ្គង់ និងក្រុមការងារក្នុងប្រទេសកម្ពុជាតែងតែផ្តល់ការគាំទ្រឥតឈប់ឈរ ដែលជួយជម្រុញឲ្យក្រុមហ៊ុនឆ្ពោះទៅមុខ ទោះក្នុងកាលៈទេសៈណាក៏ដោយ។

អរគុណ

ព្រះរាជាណាចក្រកម្ពុជា ប៉េសទិក (ខេមបូឌា) ម.ក PESTECH (CAMBODIA) PLC KINGDOM OF CAMBODIA

PAUL LIM PAY CHUAN

**ប្រធានក្រុមប្រឹក្សាភិបាល**

ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣

PESTECH

# សេចក្តីថ្លែងរបស់ប្រធាននាយកប្រតិបត្តិ

ភាគហ៊ុនិកជាទីរាប់អាន

ទោះបីជាមានការខិតខំប្រឹងប្រែងដ៏ល្អបំផុតរបស់យើងក៏ដោយ កត្តាមិនអំណោយផលខាងក្រៅបាននាំមកនូវបញ្ហាប្រឈមសម្រាប់ពួកយើងក្នុងការផ្តល់នូវលទ្ធផលហិរញ្ញវត្ថុជាវិជ្ជមានក្នុងអំឡុង Q២ នៃឆ្នាំហិរញ្ញវត្ថុ ២០២៣ នេះ។

យ៉ាងណាមិញ យើងបានខិតខំពុះពារឆ្លងកាត់ត្រីមាសរាយការណ៍នេះជាមួយនឹងលទ្ធផលល្អប្រសើរជាងត្រីមាសមុន ដោយការរាយការណ៍ពីប្រាក់ចំណេញប្រតិបត្តិការកាន់តែប្រសើរ ដែលផ្នែកអាជីវកម្មប្រតិបត្តិការ និងការថែទាំ បានចូលរួមចំណែកដ៏សំខាន់។

ផ្នែកប្រតិបត្តិគម្រោងបានសង្កេតឃើញការវិវត្តន៍មិនសូវរលូនជាមួយនឹងសកម្មភាពសំខាន់ៗដែលទាញចេញពីគម្រោងភ្នំពេញទៅព្រំដែនកម្ពុជា-ឡាវ រួមជាមួយនឹងគម្រោងខ្សែក្រោមដី ២៣០kV ដែលផ្តល់មូលនិធិដោយ JICA ។ យើងសង្ឃឹមថានឹងអាច ផ្តល់នូវការអនុវត្តគម្រោងក្នុងកម្រិតដ៏ខ្ពស់មួយ ជាពិសេសបន្ទាប់ពីយើងបានបញ្ចប់ការរៀបចំហិរញ្ញប្បទានគម្រោងសម្រាប់គម្រោងទាំងពីរនាពេលខាងមុខនេះ។

ក្នុងអំឡុងត្រីមាសទី ២ យើងទទួលបានជោគជ័យក្នុងការបង្កើតនូវប្រព័ន្ធផលិតថាមពលអគ្គិសនីលើដំបូលដែលមានកម្លាំង ៧៥០kWp សម្រាប់រោងចក្រនៅខេត្តកណ្តាលសម្រាប់ក្រុមហ៊ុន TotalEnergies ។ ក្រុមការងាររបស់យើងពោរពេញទៅដោយបទពិសោធន៍ក្នុងការរចនា វិស្វកម្ម និងការអនុវត្ត លើគ្រឿងបរិក្ខារប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យនៅលើដំបូល។ យើងក៏មានសមត្ថភាពផ្តល់ជូននូវការគ្រប់គ្រងគម្រោងជាមួយនឹងស្តង់ដារគុណភាព និងតម្រូវការដ៏ចាំបាច់ផងដែរ។ ដោយហេតុនេះ យើងនឹងបន្តរួមចំណែកក្នុងការលើកកម្ពស់ការអភិវឌ្ឍថាមពលប្រកបដោយនិរន្តរភាព ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលកម្ពុជាក្នុងការធ្វើសមាហរណកម្មធនធានថាមពលកកើតឡើងវិញយ៉ាងសកម្មទៅក្នុងល្បាយថាមពលរបស់ខ្លួន។

សម្ព័ន្ធក្រុមហ៊ុននៅតែមានគំនិតសុទិដ្ឋិនិយមចំពោះលទ្ធផលការងារនាពេលអនាគតរបស់ខ្លួន ដោយផ្តោតលើគម្រោងផ្តល់ចំណូលរហ័សដោយសមហេតុផល ជាមួយនឹងការចំណាយដើមទុនតិចតួចបំផុត។ យើងខិតខំផ្តល់នូវអ្វីដែលល្អបំផុត និងបង្ហាញពីការដឹងគុណរបស់យើងចំពោះភាគហ៊ុនិក អតិថិជន អ្នកផ្គត់ផ្គង់ និងក្រុមការងាររបស់យើង សម្រាប់ទំនុកចិត្ត និងការគាំទ្រដើម្បីការអភិវឌ្ឍន៍របស់យើង។

សូមអរគុណ

PESTECH (CAMBODIA) PLC
KINGDOM OF CAMBODIA

HAN FATT JUAN

**នាយកប្រតិបត្តិ**

ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣

PESTECH

# មាតិកា


ព័ត៌មានហិរញ្ញវត្ថុសង្ខេប ....................................................................................................i

សមាសភាពក្រុមប្រឹក្សាភិបាល ....................................................................................................ii

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល....................................................................................................iii

សេចក្តីថ្លែងប្រធាននាយកប្រតិបត្តិ ....................................................................................................iv

**ផ្នែកទី១៖ ព័ត៌មានទូទៅនៃក្រុមហ៊ុន ចុះបញ្ជី**

ក. អត្តសញ្ញាណក្រុមហ៊ុនចុះបញ្ជី

ខ. សកម្មភាពអាជីវកម្ម

គ. ព្រឹត្តិការណ៍សំខាន់ប្រចាំត្រីមាស

**ផ្នែកទី២៖ ព័ត៌មានពីលទ្ធផលប្រតិបត្តិការអាជីវកម្ម**

ក. លទ្ធផលប្រតិបត្តិការជីវកម្ម

ខ. រចនាសម្ព័ន្ធចំណូល

**ផ្នែកទី៣៖ របាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានត្រួតពិនិត្រឡើងវិញដោយសវនកងករាជ្យ**

**ផ្នែកទី៤៖ កិច្ចពិភាក្សា និងវិភាគរបស់គណៈគ្រប់គ្រង**

ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

ខ. កត្តាសំខាន់ៗដែលជះឥទ្ធិពលលើផលចំណេញ

គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងប្រាក់ចំណូល

ឃ. ផលប៉ះពាល់នៃអត្រាប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងតម្លៃទំនិញ

ង. ផលប៉ះពាល់នៃអតិផរណា

ច. សេដ្ឋកិច្ច សារពើពន្ធ គោលនយោបាយរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

**ផ្នែកទី៥៖ ព័ត៌មានសំខាន់ៗដ៏ទៃផ្សេងទៀតសម្រាប់ការការពារវិនិយោគិន**

ហត្ថលេខារបស់អភិបាលនៃក្រុមហ៊ុនចុះបញ្ជី

PESTECH

## ផ្នែកទី១៖ ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ

ក. អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាភាសាខ្មែរ | ផេសថិក (ខេមបូឌា) ម.ក |
| ជាអក្សរឡាតាំង | **PESTECH (CAMBODIA) PLC** |
| លេខកូដស្តង់ដារ | KH១០០០១៥០០០៩ |
| និមិត្តសញ្ញា | ផថខ |
| អាសយដ្ឋាន | អគារលេខ ៣៥ ជាន់ទី១០ ផ្លូវម៉ៅសេទុង ភូមិ៩ សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ |
| លេខទូរស័ព្ទ | +៨៥៥ ២៣ ៨៨២ ១០៥ |
| លេខទូរសារ | +៨៥៥ ២៣ ៨៨២ ១០៦ |
| គេហទំព័រ | www.pestech.com.kh |
| អ៊ីមែល៖ | info@pestech.com.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០០០៩៥៧ ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១០ ចេញដោយក្រសួងពាណិជ្ជកម្ម |
| លេខអាជ្ញាប័ណ្ណអាជីវកម្ម | ៣២៦ ប្រក.ជនស.អសណ ចេញដោយ ជនស ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០១៨ |
| សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានលេខ | ១៧១/២០ គ.ម.គ/ស.ស.រ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០២០ ចេញដោយ គណៈកម្មការមូលបត្រកម្ពុជា (បច្ចុប្បន្នជានិយ័តករមូលបត្រកម្ពុជា "នមក") |
| ឈ្មោះបុគ្គលតំណាងបុគ្គលចុះបញ្ជីលក់មូលបត្រ | លោក Paul Lim Pay Chuan |

ខ. ប្រភេទអាជីវកម្ម

ផថខ បានរួមចំណែកជាចម្បងក្នុងការផ្តល់ វិស័យវិស្វកម្ម និងដំណោះស្រាយបច្ចេកទេសនៃប្រព័ន្ធអគ្គីសនីដ៏ទូលំទូលាយសម្រាប់៖

- ការរចនាប្លង់ លទ្ធកម្ម សាងសង់ តម្លើង និងការដាក់ឱ្យប្រើប្រាស់អនុស្ថានីយ៍ HV និង EHV ខ្សែបញ្ជូនអគ្គីសនី HV និង EHV ព្រមទាំងប្រព័ន្ធខ្សែកាបអគ្គីសនីក្រោមដីសម្រាប់បញ្ជូន និងចែកចាយអគ្គីសនីផងដែរ
- កិច្ចដំណើរការ និងការថែទាំ ("O&M") ខ្សែបញ្ជូនអគ្គីសនី និងអនុស្ថានីយ៍ និង
- ការធ្វើពាណិជ្ជកម្ម បរិក្ខារប្រព័ន្ធអគ្គីសនី និងឧបករណ៍ ជាកម្មសិទ្ធិ និងមិនមែនជាកម្មសិទ្ធិ

គ. ព្រឹត្តិការណ៍សំខាន់ប្រចាំត្រីមាស

នៅថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២២ ផថខ បានធ្វើកិច្ចប្រជុំមហាសន្និបាតប្រចាំឆ្នាំនៅសណ្ឋាគារ ហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ ។ កិច្ចប្រជុំនោះមានភាគហ៊ុនិកចំនួន ១៩នាក់ និងអ្នកតំណាងចំនួន ៤នាក់ បានចូលរួម ដែលមានភាគហ៊ុនសរុបចំនួន ៧១ ៦៦៥ ៨៣៥ ហ៊ុន។ ភាគហ៊ុនិកបោះឆ្នោតនិងបានអនុម័តសេចក្តីសម្រេចចំនួនប្រាំ (៥)។ រូបភាពខាងក្រោមជាសកម្មភាពរបស់ភាគហ៊ុនិកក្នុងកិច្ចប្រជុំមហាសន្និបាត។




BALLOT BOX




PESTECH

PESTECH

## ផ្នែកទី២៖ ព័ត៌មានអំពីលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម

### ក. លទ្ធផលនៃប្រតិបត្តិការអាជីវកម្មតាមផ្នែក

កិច្ចសន្យាលើ វិស្វកម្ម លទ្ធកម្ម ការសាងសង់ និងការដាក់អោយដំណើរការ ("EPCC") សម្រាប់បណ្ដាញអគ្គិសនី និងអនុស្ថានីយ៍ គឺជាកត្តាចូលរួមសំខាន់ចំពោះប្រាក់ចំណូលប្រចាំត្រីមាស ក្រោមការត្រួតពិនិត្យដែលមានទឹកប្រាក់ចំនួន ១៥ ៧០៥ លានរៀល (ត្រីមាសទីពីរនៃឆ្នាំហិរញ្ញវត្ថុ ២០២២៖ ៥៥ ០៧៩ លានរៀល) ដែលស្មើនឹងប្រមាណ ៨២,២% (ត្រីមាសទីពីរនៃឆ្នាំហិរញ្ញវត្ថុ ២០២២៖ ៩៤,៥%) នៃចំណូលសរុប។

ការបំពេញបន្ថែមលើសេវាកម្ម EPCC របស់យើងដែលជាប្រតិបត្តិការ និងសកម្មភាពថែទាំ("O&M") ការកត់ត្រាប្រាក់ចំណូល មានទឹកប្រាក់ចំនួន ៣ ៤០១ លានរៀល (ប្រហែល ៨២៤ ០០០ ដុល្លាអាមេរិច) ដែលស្មើនឹង ១៧,៨% នៃចំណូលសរុប (ត្រីមាសទីពីរនៃឆ្នាំហិរញ្ញវត្ថុ ២០២២៖ ៣ ១៩៥ លានរៀល ឬ ៥,៥%)។

ក្នុងកំឡុងត្រីមាសនេះ សម្ព័ន្ធក្រុមហ៊ុនបានទទួលស្គាល់ចំណូលហិរញ្ញប្បទានមានចំនួន ២ ៧៤០ លានរៀល (ត្រីមាសទីពីរ ឆ្នាំ ២០២២៖ ២ ៩៧២ លានរៀល) សម្រាប់កិច្ចសន្យាដាក់លាក់ជាមួយអតិថិជន ស្របតាមការអនុលោមស្តង់ដា របាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ១៥ ("CIFRS") ។ចំណូលហិរញ្ញប្បទានគឺជាផ្នែកមួយនៃប្រាក់ចំណូលសរុបរបស់យើងនៅក្នុងសម្ព័ន្ធ។

### ខ. រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល | ត្រីមាសទី២ ឆ្នាំ២០២៣ | | ត្រីមាសទី២ ឆ្នាំ២០២២ | | ត្រីមាសទី២ ឆ្នាំ២០២១ | |
|---|---|---|---|---|---|---|---|
| | | លានរៀល | ភាគរយ | លានរៀល | ភាគរយ | លានរៀល | ភាគរយ |
| ១ | ("EPCC) កិច្ចសន្យាសម្រាប់អគ្គិសនី និងអនុស្ថានីយ៍ | ១៥ ៧០៥ | ៨២,២ | ៥៥ ០៧៩ | ៩៤,៥ | ៣២ ៧២៤ | ៩១,១ |
| ២ | ប្រតិបត្តិការ និងសេវាថែទាំ | ៣ ៤០១ | ១៧,៨ | ៣ ១៩៥ | ៥,៥ | ៣ ២០០ | ៨,៩ |
| | ប្រាក់ចំណូលសរុប | ១៩ ១០៦ | ១០០,០ | ៥៨ ២៧៤ | ១០០,០ | ៣៥ ៩២៤ | ១០០,០ |

| ល.រ | ប្រភពចំណូលកិច្ចសន្យា | ត្រីមាសទីពីរ ឆ្នាំ ២០២៣ | | ត្រីមាសទីពីរ ឆ្នាំ ២០២២ | | ត្រីមាសទីពីរ ឆ្នាំ ២០២១ | |
|---|---|---|---|---|---|---|---|
| | | លានរៀល | ភាគរយ | លានរៀល | ភាគរយ | លានរៀល | ភាគរយ |
| ១ | ប្រាក់ចំណូល | ១៩ ១០៦ | ៨៧,៥ | ៥៨ ២៧៤ | ៩៥,១ | ៣៥ ៩២៤ | ១០០,០ |
| ២ | ចំណូលហិរញ្ញប្បទានសម្រាប់ទ្រព្យសកម្មកិច្ចសន្យា | ២ ៧៤០ | ១២,៥ | ២ ៩៧២ | ៤,៩ | គ្មាន | គ្មាន |
| | ប្រាក់ចំណូលកិច្ចសន្យាសរុប | ២១ ៨៤៦ | ១០០,០ | ៦១ ២៤៦ | ១០០,០ | ៣៥ ៩២៤ | ១០០,០ |

PESTECH

## ផ្នែកទី៣៖ របាយការណ៍ហិរញ្ញវត្ថុពិនិត្យដោយសវនករខាងក្រៅ

សូមយោងទៅតាមរបាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយត្រូវបានធ្វើការត្រួតពិនិត្រឡើងវិញរួចរាល់ហើយដោយសវនករឯករាជ្យ។

## ផ្នែកទី៤៖ កិច្ចពិភាក្សា និងវិភាគរបស់គណៈគ្រប់គ្រង ("MD&A")

### ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

១. ការវិភាគចំណូល

ចំណូលសរុបសម្រាប់បីខែនៃរយៈពេលហិរញ្ញវត្ថុ ដែលបានបញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២២ បានកត់ត្រាត្រឹម ១៩ ១០៦ លានរៀល ដោយថយចុះចំនួន ៣៩ ១៦៨ លានរៀល ឬ ៦៧,២% បើប្រៀបធៀបទៅនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន បានកត់ត្រាត្រឹម ៥៨ ២៧៤ លានរៀល ។ បម្រែបម្រួលនៃប្រាក់ចំណូលបានឆ្លុះបញ្ចាំងពីវឌ្ឍភាពនៃការអនុវត្តគម្រោងផ្សេងៗក្នុងប្រទេសកម្ពុជា។ប្រាក់ចំណូលទាបនៅក្នុងត្រីមាសបច្ចុប្បន្នដែលស្ថិតនៅក្រោមការត្រួតពិនិត្យគឺបណ្តាលមកពីការបញ្ចប់នៃគម្រោងនៅបាវិតនាខែ មករា ឆ្នាំ ២០២២ ហើយមានការវិវឌ្ឍន៍នៃគម្រោងភាគខាងកើតនៃខេត្តសៀមរាបដែលកំពុងដំណើរការបន្តបន្ទាប់រហូតដល់បញ្ចប់នៃវដ្តគម្រោង ក៏ដូចជាវឌ្ឍនភាពនៃគម្រោងតាមព្រំដែនប្រទេសឡាវបើប្រៀបធៀបនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន។

### ២. ការវិភាគចំណូលតាមផ្នែក

កិច្ចសន្យាលើ វិស្វកម្ម លទ្ធកម្ម ការសាងសង់ និងការដាក់អោយដំណើរការ ("EPCC") សម្រាប់បណ្តាញអគ្គិសនី និងអនុស្ថានីយ៍ គឺជាកត្តាចូលរួមសំខាន់ចំពោះប្រាក់ចំណូលប្រចាំត្រីមាសក្រោមការត្រួតពិនិត្យឡើងវិញ ដែលមានទឹកប្រាក់ចំនួន ១៥ ៧០៥ លានរៀល (ត្រីមាសទីពីរនៃឆ្នាំហិរញ្ញវត្ថុ ២០២២៖ ៥៥ ០៧៩ លានរៀល) ដែលស្មើនឹងប្រមាណ ៨២,២% (ត្រីមាសទីពីរនៃឆ្នាំហិរញ្ញវត្ថុ ២០២២៖ ៩៤,៥%) នៃចំណូលសរុប។

ការបំពេញបន្ថែមលើសេវាកម្ម EPCC របស់យើងដែលជាប្រតិបត្តិការ និងសកម្មភាពថែទាំ("O&M") ការកត់ត្រាប្រាក់ចំណូលមានទឹកប្រាក់ចំនួន ៣ ៤០១ លានរៀល (ប្រហែល ៨២៤ ០០០ ដុល្លាអាមេរិច) ដែលស្មើនឹង ១៧,៨% នៃចំណូលសរុប (ត្រីមាសទីពីរនៃឆ្នាំហិរញ្ញវត្ថុ ២០២២៖ ៣ ១៩៥ លានរៀល ឬ ៥,៥%)។

### ៣. ការវិភាគគម្លាតចំណេញដុល

ចំណេញដុលនៅក្នុងត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញ បានកត់ត្រាមានចំនួនត្រឹម ៤៧,៨% បើ ប្រៀបធៀបទៅនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន មានចំនួន ១៦,៥% ដោយកើនឡើងចំនួន ៣១,៣%។ ចំណេញដុលខ្ពស់ជាងត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញ ពីសកម្មភាពថែទាំ("O&M") ។ សរុបមក ចំណេញដុលសម្រាប់រយៈពេលបច្ចុប្បន្នគឺស្ថិតនៅក្នុងការរំពឹងទុករបស់សម្ព័ន្ធក្រុមហ៊ុន។

### ៤. ការវិភាគចំណេញមុនបង់ពន្ធ

ខាតមុនបង់ពន្ធសម្រាប់ត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញ ត្រូវបានកត់ត្រាត្រឹម ១ ៧៦៩ លានរៀល បើប្រៀបធៀបទៅនឹងការចំណេញមុនពេលបង់ពន្ធមានចំនួន ១ ៣២៤ លានរៀល ក្នុងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន ដោយថយចុះចំនួន ៣ ០៩៣ លានរៀល ឬ ២៣៣,៦% ។ ខាតមុនបង់ពន្ធជាកត្តាចម្បងដែលបានមកពីការទទួលស្គាល់ប្រាក់ចំណូលទាបសម្រាប់ត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញ បើប្រៀបធៀបទៅនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន។

PESTECH

## ៥. ការវិភាគ(ខាត)/ចំណេញក្នុងការិយបរិច្ឆេទ

ការខាតក្រោយដកពន្ធនៃត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញមានចំនួនត្រឹម ២ ២៩៧ លានរៀល បើប្រៀបធៀបទៅនឹងចំណេញក្រោយដកពន្ធមានចំនួន ៦៥៦ លានរៀល ក្នុងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុនដោយថយចុះមានចំនួន ២ ៩៥៣ លានរៀល ឬ ៤៥០,២% ។

## ខ. កត្តាសំខាន់ដែលជះឥទ្ធិពលលើប្រាក់ចំណេញ

អំឡុងពេលក្រោមការត្រួតពិនិត្យឡើងវិញនេះ មិនមានកត្តាសំខាន់ៗណាមួយដែលជះឥទ្ធិពលលើប្រាក់ចំណេញរបស់ប្រតិបត្តិការចំពោះសម្ព័ន្ធក្រុមហ៊ុនឡើយ។

## គ. ការប្រែប្រួលសំខាន់ៗនៃការលក់ និងប្រាក់ចំណេញ

ចំណូលសរុបសម្រាប់បីខែនៃរយៈពេលហិរញ្ញវត្ថុ ដែលបានបញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២២ បានកត់ត្រាត្រឹម ១៩ ១០៦ លានរៀល ដោយថយចុះចំនួន ៣៩ ១៦៨ លានរៀល ឬ ៦៧,២% បើប្រៀបធៀបទៅនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន បានកត់ត្រាត្រឹម ៥៨ ២៧៤ លានរៀល ។ បម្រែបម្រួលនៃចំណូលសរុបបានឆ្លុះបញ្ចាំងពីវឌ្ឍនភាពនៃការអនុវត្តគម្រោងផ្សេងៗក្នុងប្រទេសកម្ពុជា។ ប្រាក់ចំណូលទាបនៅក្នុងត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញគឺបណ្តាលមកពីការបញ្ចប់គម្រោងនៅបាវិត នាខែ មករា ឆ្នាំ២០២២ ហើយមានការវិវឌ្ឍន៍នៃគម្រោងភាគខាងកើតនៃខេត្តសៀមរាប ដែលត្រូវបានដំណើរការជាបន្តបន្ទាប់រហូតដល់ ការបញ្ចប់នៃវត្តគម្រោង ក៏ដូចជាវឌ្ឍនភាពនៃគម្រោងតាមព្រំដែននៃប្រទេសឡាវបើប្រៀបធៀបនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន។

## ឃ. ផលប៉ះពាល់នៃការប្តូររូបិយបណ្ណបរទេស អត្រាការប្រាក់ និងតម្លៃទំនិញ

ការកើនឡើងនៃអត្រាLIBOR នាពេលថ្មីៗនេះបានមកពីការកើនឡើងនៃចំណាយហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន។ ទោះបីជាមានការកើនឡើងនៃអត្រា LIBOR ក៏ដោយ ក៏សម្ព័ន្ធក្រុមហ៊ុនបានចុះកិច្ចសន្យាលើគម្លាតអត្រាការប្រាក់នៃកិច្ចសន្យាបញ្ជាំ ផលប៉ះពាល់របស់សម្ព័ន្ធក្រុមហ៊ុនពីហានិភ័យអត្រាការប្រាក់លើឥណទានមានការកំណត់ដែលអនុញ្ញាតអោយសម្ព័ន្ធក្រុមហ៊ុនបង្កើនប្រាក់កម្ចីក្នុងអត្រាទីផ្សារប្តូរទៅជាអត្រាថេរ។ ក្រៅពីការលើកឡើងខាងលើនេះ ពុំមានផលប៉ះពាល់ធ្ងន់ធ្ងរដែលបណ្តាលមកពីការប្តូររូបិយបណ្ណបរទេស អត្រាការប្រាក់ និងការឡើងចុះនៃតម្លៃទំនិញនោះទេ។

## ង. ផលប៉ះពាល់នៃអតិផរណា

ការចំណាយសម្រាប់អាជីវកម្មរបស់យើង គឺដោយសារផលប៉ះពាល់នៃអតិផរណាដែលមានចំនួនប្រហែល ២៨% នៃចំណូលរបស់យើង។ ទោះបីជាយ៉ាងណាក៏ដោយ អតិផរណានៅក្នុងប្រទេសកម្ពុជា មានចំនួន ៤,៩% ( គិតត្រឹមថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០២២ ប្រភព៖ *Fibre2Fashion :អត្រាអតិផរណារបស់ប្រទេសកម្ពុជាធ្លាក់ចុះមកត្រឹម ៤,៩% ក្នុងត្រីមាសទីបី ឆ្នាំ ២០២២ ពី ៧,៤% ក្នុងត្រីមាសទីពីរ* ) ដែលបានបង្កផលប៉ះពាល់ប្រហែល ១,៣៧% ប៉ុណ្ណោះ ចំពោះប្រាក់ចំណេញរបស់យើង ។ រាល់ចំណាយប្រតិបត្តិការទាំងអស់ មានតម្លៃថេរ នៅក្នុងរយៈពេលនៃកិច្ចសន្យាទាំងមូល។ ក្រៅពីការលើកឡើងខាងលើនេះ ពុំមានផលប៉ះពាល់សំខាន់ៗផ្សេងទៀត ដែលបណ្តាលមកពីអតិផរណានោះទេ។

## ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ រូបិយវត្ថុរបស់រាជរដ្ឋាភិបាល

ពុំមានបម្រែបម្រួលសំខាន់ៗនៅក្នុងគោលនយោបាយសេដ្ឋកិច្ច/សារពើពន្ធ/សាច់ប្រាក់របស់រាជរដ្ឋាភិបាល ឬ កត្តានានាដែលមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះលទ្ធផលហិរញ្ញវត្ថុនៅក្នុងអំឡុងឆ្នាំនេះនោះទេ។

## ផ្នែកទី ៥៖ ព័ត៌មានសំខាន់ៗដទៃទៀតសម្រាប់ការការពារវិនិយោគិន

ពុំមានព័ត៌មានដែលចាំបាច់ផ្សេងទៀតសម្រាប់ការការពារវិនិយោគិន។

PESTECH

**ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ**

ថ្ងៃចន្ទ ៨ រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ពស ២៥៦៦

ថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០២៣

បានអាន និងឯកភាព

**ហត្ថលេខា**

ព្រះរាជាណាចក្រកម្ពុជា
ភេសថិក (ខេមបូឌា) ម.ក
PESTECH (CAMBODIA) PLC
KINGDOM OF CAMBODIA

**PAUL LIM PAY CHUAN**

ប្រធានក្រុមប្រឹក្សាភិបាល